00602599

D404/2/1

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
09 / 09 / 2010
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
14 / 09 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**នៅចំពោះមុខ អង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស (PTC ៧៣)

ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស / អបជ: សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចអំពីការទទួលយកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីក្រៅប្រទេស D404**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក នី ចាន់ឌី

លោកស្រី Lyma NGUYEN

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

<u>ផ្ញើជូន៖</u>

**អង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន៍យ ធុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Catherine MARCHI-UHEL

ចៅក្រម Rowan DOWNING

00602600

**មេធាវីតំណាងភាគីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក គង់ ពិសី

លោក យ៉ុង ផានិត

លោកស្រី ស៊ិន សុវ៉ន

លោក គីម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី ជេត វណ្ណលី

លោក ពេជ អង្គ

លោក វ៉ែន ពៅ

លោក ហុង គីមសួន

លោកស្រី Martine JACQUIN

លោក Phillipe CANONNE

លោកស្រី Elizabeth RABESANDRATANA

លោកស្រី Annie DELAHAIE

លោក Olivier BAHOUGNE

លោក Mahdev MOHAN

លោកស្រី Marie GUIRAUD

លោក Patrick BAUDOIN

លោកស្រី Fabienne TRUSSES-NAPROUS

អ្នកស្រី Silke STUDZINSKY

លោក Ferdinand DJAMMEN-NZEPA

លោកស្រី Christine MARTINEAU

លោកស្រី Laure DESFORGES

លោកស្រី Isabelle DURAND

លោក Emmanuel ALTIT

លោក Emmanuel JACOMY

លោក Barnabe NEKUIE

**សហមេធាវីការពារក្តីជនត្រូវចោទ៖**

**អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS

**នួន ជា**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGES

**កាំង ហ្គេកអ៊ាវ ហៅ ឌុច**

លោក ការ សាវុត្ថ

លោក កង ឫទ្ធារី

00602601

លោក Daniel LOSQ

លោក Julien RIVET

លោក Pascal Aubion

លោកស្រី Francoise GAUTRY

លោក ឡោ ជុនធី

## សំណើជាបន្ទាន់សុំបន្ថែមចំនួនទំព័រដើម្បីដាក់បណ្តឹងឧទ្ធរណ៍

១. អនុលោមតាមវិធាន ៧៧ ស្ទួន(២) នៃវិធានផ្ទៃក្នុងរបស់ អវតក (វិធានផ្ទៃក្នុង) សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានបំណងដាក់បណ្តឹងឧទ្ធរណ៍ជាបន្ទាន់ តំណាងឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមកពីក្រៅប្រទេស ("បណ្តឹងឧទ្ធរណ៍")។ អនុលោមតាមវិធាន ៧៥ នៃវិធានផ្ទៃ សេចក្តីជូនដំណឹងពីការដាក់បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ជូនរួចមកហើយ[១]។

២. បណ្តឹងឧទ្ធរណ៍ដែលមានបំណងដាក់ជូននេះ នឹងមានកម្រាស់លើសពី ៣០ (សាមសិប) ទំព័រដូចដែលបានកំណត់ជាភាសាអង់គ្លេស។ បណ្តឹងឧទ្ធរណ៍នេះនឹងមានចំនួនប្រហែល៥៥ទំព័រ ដោយមិនរាប់បញ្ចូលទំព័រចំណងជើង ទំព័រឯកសារយោង និងទំព័រឧបសម្ព័ន្ធនោះទេ)។ អនុលោមតាមមាត្រា ៥.៤ នៃ *សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អវតក*[២] យើងខ្ញុំស្នើសុំឱ្យចៅក្រមនៃអង្គបុរេជំនុំជម្រះអនុវត្តឆន្ទានុសិទ្ធ ដើម្បីអនុញ្ញាតឱ្យមានការបន្ថែមចំនួនទំព័រ ដោយសារតែកាលៈទេសៈពិសេសមួយចំនួន ដូចខាងក្រោមនេះ ៖

ក. បណ្តឹងឧទ្ធរណ៍នេះ ពាក់ព័ន្ធទៅនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាច្រើននាក់។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤នាក់ នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ តំណាងឱ្យអ្នកដាក់បណ្តឹងមកពីក្រៅប្រទេស រួមទាំង អ្នកមកពីសហរដ្ឋអាមេរិក និងអូស្ត្រាលីផងដែរ។

ខ. អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣នាក់ ដែលបានដាក់បញ្ចូលនៅក្នុងបណ្តឹងឧទ្ធរណ៍នេះទើបតែត្រូវបានចាត់ឱ្យមានមេធាវី តាមរយៈលិខិតចាត់តាំងរបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០១០ កន្លងមកនេះ។ ដោយសារតែកូនក្តីទាំងនេះមិនដែលមានឱកាសទទួលបានការប្រឹក្សាផ្នែកច្បាប់ អំពីការដាក់ព័ត៌មានបន្ថែមនោះ មានការ

---

[១] ការដាក់ការជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងនៅថ្ងៃ ០៩ ខែកញ្ញា ឆ្នាំ២០១០ ដោយលោក នី ចាន់ឌី និងកញ្ញា Lyma NGUYEN។ ក្នុងពេលជូនដំណឹងនេះ លេខឯកសារមិនទាន់មាននៅឡើយទេ។

[២] សេចក្តីណែនាំអនុវត្ត អវតក/០១/២០០៧/វិសោធនកម្មលើកទី ៤។

រំពឹងទុកថា "ឯកសារគាំទ្រ" ដែលជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍នេះ នឹងត្រូវផ្ដល់សម្រាប់កូនក្ដីទាំងនោះ ដោយអនុលោមតាមវិធាន ៧៧ ស្ទួន(២) នៃវិធានផ្ទៃក្នុង។ វានឹងបណ្ដាលឲ្យមានភាពអយុត្តិធម៌ ចំពោះអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើខ្លឹមសារនៃបណ្ដឹងឧទ្ធរណ៍រួមត្រូវបានកំហិតឲ្យមានកម្រាស់ត្រឹមចំនួន ៣០ ទំព័រ ដែលនេះគឺជាការបង្ខំឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី កាត់បន្ថយខ្លឹមសារផ្នែកអង្គហេតុ និងអង្គច្បាប់យ៉ាងច្រើន ដែលជាសំអាង នៃបណ្ដឹងឧទ្ធរណ៍នេះ។

គ. លើសពីនេះទៅទៀត និង/ឬ ជាជម្រើស ការបន្ថែមចំនួនទំព័រគួរតែត្រូវបានអនុញ្ញាត ដោយសារវាជាឧត្តមប្រយោជន៍ដ៏ធំធេងនៃភាពត្រឹមត្រូវ យុត្តិធម៌ និងភាពគ្រប់គ្រាន់នៃនីតិវិធី និងការរៀបចំ សម្រាប់អង្គភាពទាំងអស់របស់ អវតក រួមទាំងផ្នែកបកប្រែភាសា និងផ្នែកគ្រប់គ្រងសំណុំរឿងរបស់សាលាក្ដីនេះផងដែរ ដើម្បីឲ្យបណ្ដឹងឧទ្ធរណ៍ចំនួន១៤អាចធ្វើនៅក្នុងសំណើសុំតែមួយ ជាជាងឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដាក់បណ្ដឹងឧទ្ធរណ៍ដាច់ដោយឡែកពីគ្នា។

៣. ដោយសារតែភាពបន្ទាន់នៃបណ្ដឹងឧទ្ធរណ៍ (ដែលត្រូវដាក់នៅត្រឹមថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០) យើងខ្ញុំសូមថ្លែងអំណរគុណដល់អង្គបុរេជំនុំជម្រះ ចំពោះការឆ្លើយតបយ៉ាងឆាប់រហ័សតាមដែលអាចធ្វើទៅបាន ទៅនឹងសំណើរបស់យើងខ្ញុំ សុំអនុញ្ញាតបន្ថែមចំនួនទំព័រ។

សូមលោកចៅក្រមមេត្តាទទួលយកសំណើសុំនេះដោយអនុគ្រោះ។

ហត្ថលេខា

នី ចាន់ឌី

Lyma NGUYEN